

# មុខរបរ

## Komar Rien Komar Cheh

Chantha Rathana, Meth Phearum

Let's Read
The Asia Foundation



ពូសំ ជាកសិករ។ គាត់កំពុងភ្ជួរស្រែ។




មីងសុផា ជាគ្រូបង្រៀនថ្នាក់ទី១។ គាត់កំពុងបង្រៀនសិស្ស។



ពូសាន ជាជាងជួសជុលឡាន។ គាត់កំពុងពិនិត្យមើលម៉ាស៊ីនឡាន។




មីងចាន់ណា ជាប៉ូលិសចរាចរណ៍។ គាត់កំពុងជួយសម្រួលចរាចរណ៍នៅលើដងផ្លូវ។



ពូសារឿន ជាមេចុងភៅ។ គាត់កំពុងចម្អិនម្ហូបជូនភ្ញៀវ។



បងស្រីរ៉ានី ជាវេជ្ជបណ្ឌិតផ្នែកជំងឺកុមារ។ គាត់កំពុងពិនិត្យអ្នកជំងឺ។



ពូបូរ៉ា ជាជាងកាត់ដេរ។ គាត់កំពុងកាត់សម្លៀកបំពាក់គ្រប់ម៉ូត។



បងស្រីទេពី ជាកីឡាករតៃក្វាន់ដូ។ គាត់កំពុងហាត់រៀនដើម្បីត្រៀមប្រកួត។



បងខៀវ ជាវិស្វករស្ពានថ្នល់។ គាត់កំពុងពិនិត្យមើលកម្មករសាងសង់ស្ពាន។



បងស្រីលីនដា ជាអ្នកបើកយន្តហោះ។ គាត់កំពុងត្រៀមខ្លួន
ដើម្បីបើកយន្តហោះជូនភ្ញៀវ។



ពូសុជាតិ ជាអ្នកបើកយានអវកាស។ គាត់កំពុងត្រៀមខ្លួនដើម្បីបើកយានអវកាសទៅកាន់ភពព្រះចន្ទ។




បងស្រី បងប្រុស ពូ មីង មានការងារធ្វើផ្សេងៗគ្នា។ ពួកគាត់ពេញចិត្តនឹងមុខរបររបស់គាត់។



**សំណួរ**

១. តើ មីងសុផា មានមុខរបរជាអ្វី? តើគាត់កំពុងធ្វើអ្វី?

២. តើ ពូបូរ៉ា មានមុខរបរជាអ្វី? តើគាត់កំពុងធ្វើអ្វី?

៣. តើកូនដឹងទេថា ហេតុអ្វីបានជា បងស្រីរ៉ានី កំពុងពិនិត្យអ្នកជំងឺ?

៤. នៅពេលធំឡើង តើកូនចង់មានមុខរបរអ្វី? ហេតុអ្វី?

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*មុខរបរ (Different Occupations)*, Author: Komar Rien Komar Cheh. Illustrator: Chantha Rathana, Meth Phearum. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by/4.0/

Contributing translators: Chheang Chansomey